# របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងឆមាសទី១ ឆ្នាំ២០១៦ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. **ស្ថានភាពមន្ត្រីរាជការ÷**

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ៣២ នាក់ ស្ត្រី ០៤ នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. **សកម្មភាពថ្នាក់ដឹកនាំមន្ទីរ÷**

- ចូលរួមវេទិកាសាធារណៈចំនួន ១៨ ដង ។
- ចូលរួមប្រជុំក្រុមប្រឹក្សាខេត្តចំនួន ០៦ ដង ។
- ប្រជុំបូកសរុបលទ្ធផលការងារគ្រប់វិស័យចំនួន ៥ដង និងប្រជុំត្រីមាសចំនួន១ដង ។
- ចូលរួមពិធីបិទការប្រកួតបាលទាត់ ថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៦ នៅពហុកីឡាដ្ឋានខេត្តក្រចេះ ។
- ចូលរួមប្រជុំស្តីពីការចុះសិក្សាស្រាវជ្រាវវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ថ្ងៃទី ១២ ខែមករា ឆ្នាំ ២០១៦ សាលប្រជុំសាលាខេត្ត ។
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបើក និងបិទអង្គសន្និបាតបូកសរុប វាយតម្លៃការងារអប់រំឆ្នាំ២០១៤-១៥ និងទិសដៅបន្ត២០១៥-១៦ (បើកថ្ងៃ២១ ខែមករា ឆ្នាំ២០១៦ និងបិទថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ នៅ សាលមហោស្រពខេត្ត)
- ចូលរួមប្រជុំគណៈកម្មការនាយកមូលនិធិសមធមិប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ មន្ទីរពេទ្យបង្អែកស្រុកឆ្លូង។
- ចូលរួមប្រជុំគណៈកម្មការនាយកមូលនិធិសមធមិប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ មន្ទីរសុខាភិបាលខេត្ត។
- ចូលរួមកម្មវិធីទិវាស្រែបង្ហាញរបស់គម្រោងកសាងភាពធន់ទៅនឹងការបម្រែបម្រួលអាកាសធាតុ និងសន្តិសុខស្បៀងក្នុងសហគមន៍ ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ នៅភូមិឈើទាលភ្លោះ ឃុំកញ្ជរ ស្រុកឆ្លូង។
- ចូលរួមសិក្ខាសាលាស្តីពីប្រព័ន្ធផលិតកម្មផលិតស្រា ស ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ និងស្នួនកុមារ ។
- ចូលរួមកម្មវិធីប្រកាសតំបន់វិនិច្ឆ័យ នៃការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធជូនពលរដ្ឋ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ និងវត្តចង្ក្រង់។
- ចូលរួមពិធីបើកការដ្ឋានសាងសង់ស្ពានកំពង់រាំងថ្ងៃទី១៣ ខែកុម្ភៈ ២០១៦ ស្រុកឆ្លូង។
- ចូលរួមពិធីសម្ពោធអាគារសិក្សានៅភូមិបប្រម៉ា ថ្ងៃទី១៤ ខែកុម្ភៈ ២០១៦ ស្រុកឆ្លូង។
- ចូលរួមពិធីបញ្ចុះផ្ទាំងសិលាភ្នំសុពណ៌កាឡីថ្ងៃទី១៣ ខែកុម្ភៈ ២០១៦ ស្រុកព្រែកប្រសព្វ។
- ចូលរួមប្រជុំណែនាំដល់ប្រជាពលរដ្ឋមុខសញ្ញាទទួលបានដី៩៩៨គ្រួសារ ថ្ងៃទី១៦ ខែកុម្ភៈ ២០១៦។

- ចូលរួមចុះពិនិត្យ និងធ្វើការណែនាំដល់ពលរដ្ឋអនាធិបតេយ្យទន្រ្ទានដីព្រៃ៩៩៨ គ្រួសារ ថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំ២០១៦។
- ចូលរួមប្រជុំពិនិត្យ និងកែសម្រួលរបាយការណ៍វេទិកាសាធារណៈ ឆ្នាំ២០១៥ ថ្ងៃទី១៨ ខែកុម្ភៈ ២០១៦ នៅសាលប្រជុំសាលាខេត្តក្រចេះ។
- ចូលរួមបប្រជុំសាមញ្ញស្តីពីកិច្ចការស្រ្តី និងកុមារ ថ្ងៃទី១៨ ខែកុម្ភៈ ២០១៦ សាលប្រជុំក្រុមប្រឹក្សាខេត្ត។
- ចូលរួមពិធីសម្ពោធសមិទ្ធិផលនានានៅវត្តដារ ឃុំដារ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៦។
- ចូលរួមពិធីសម្ពោធវិទ្យាល័យថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ។
- ចូលរួមប្រជុំស្តីពីការធ្វើតារាងប្រៀបធៀបទ្រព្យសម្បត្តិកើន ថយ ឆ្នាំ២០១៥ កំណត់តម្លៃដី អាគារ វិញ្ញាបនបត្រសម្គាល់អចលនវត្ថុ ព្រមទាំងធ្វើបច្ចុប្បន្នភាពស្ថិតិអង្គភាពប្រើប្រាស់ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦ នៅសាសប្រជុំសាលាខេត្តក្រចេះ។
- ចូលរួមប្រជុំវាយតម្លៃប្រគល់ និងទទួលបញ្ចប់សុពលភាពការងារថែរទាំ ជួសជុលអណ្តូងស្នប់ នៅស្នួល និងចិត្របុរី នៅសាលប្រជុំសាលាខេត្តក្រចេះ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦។
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីសម្ពោធអាគារសិក្សាថ្មីនៅវិទ្យាល័យថ្មគ្រែ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦។
- ចូលរួមប្រជុំពិភាក្សា ស្តីពីការរៀបចំ និងបង្កើតសមាគមន៍មនុស្សចាស់តាមឃុំគោលដៅ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ នៅសាលប្រជុំមន្ទីរសង្គមកិច្ច
- ចូលរួមសិក្ខាសាលាស្តីពី ការអភិវឌ្ឍន៍បៃតង ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ នៅសាលប្រជុំសណ្ឋាគារ ហ៊ារ ប៊ុន្នី ខេត្តក្រចេះ។
- ចូលរួមជាភ្ញៀវកិត្តិយសពិធី ទិវាជាតិ អន្តរជាតិ៨មីនា នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ នៅសាលមហោស្រពខេត្តក្រចេះ។
- ចូលរួមប្រជុំពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងកម្មវិធីវិនិយោគ ៣ រំកិល ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ នៅសាប្រជុំមន្ទីរផែនការខេត្តក្រចេះ
- ចូលរួមប្រជុំសម្រេចលើទិន្នន័យដីសហគមន៍ជនជាតិដើមភាគតិចភូមិប៉ាក្លែ និងភូមិរវៀង ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ នៅសាលប្រជុំក្រុមប្រឹក្សាខេត្តក្រចេះ
- ចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពី ការជំរុញ និងកិច្ចសម្រួលការវិនិយោគនៅថ្ងៃទី២៩-៣០ មីនា ឆ្នាំ ២០១៦ នៅខេត្តមណ្ឌលគីរី។
- ចូលរួមប្រជុំពិនិត្យ និងពិភាក្សាករណីសំណើសុំដីសម្បទានសង្គមកិច្ច នៅសាលប្រជុំក្រុមប្រឹក្សាខេត្តក្រចេះ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦។
- ចូលរួមប្រជុំជាមួយគណៈកម្មាការនាយកមូលលិធិសមធម៌ប្រចាំត្រីមាសទី១ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ នៅមន្ទីរពេទ្យបង្អែកឆ្លូង និងថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ នៅមន្ទីរសុខាភិបាល។

- ចូលរួមសិក្ខាសាលាស្ដីពី បច្ចេកវិទ្យាសម្រាប់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ នៅសាលប្រជុំធំទីស្ដីការក្រសួងអភិវឌ្ឍន៍ជនបទ។
- ចូលរួមសន្និបាតបូកសរុបលទ្ធផលការងាររបស់មន្ទីរសុខាភិបាលខេត្តក្រចេះ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ នៅសាលប្រជុំមន្ទីរសុខាភិបាលខេត្តក្រចេះ។
- ចូលរួមជាភ្ញៀវកិត្តិយសពិធីសម្ពោធបើកឲ្យប្រើប្រាស់នូវអគារសម្ភពនៃមន្ទីរពេទ្យបង្អែកខេត្ត ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ បរិវេណមន្ទីរពេទ្យខេត្តក្រចេះ។
- ចូលរួមសិក្ខាសាលាស្ដីពី សម្ពោធគម្រោង ការការពារកុមារតាមសហគមន៍ នៅសណ្ឋាគារ ហ៊រ ប៊ុន្នី ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ។
- ចូលរួមប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត ដើម្បីពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងកម្មវិធីបីឆ្នាំរំកិលខេត្ត ២០១៦-២០១៨ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ សាលប្រជុំសាលា ខេត្តក្រចេះ។
- ចូលរួមប្រជុំ គ.ក.ស.ក ខេត្តថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ សាលប្រជុំក្រុមប្រឹក្សាខេត្តក្រចេះ។
- ចូលរួមពិធីផ្ដល់អណ្ដូងទឹកតាមសាលារៀននៅឃុំសោប និងឃុំជ្រោយបន្ទាយ ។
- ចូលរួមប្រជុំជាមួយក្រុមអាជ្ញាធរសវនកម្មជាតិ ស្ដីពីការចុះប្រមូលព័ត៌មានដើម្បីរៀបចំផែនការសវនកម្ម ថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១៦ សាលប្រជុំសាលាខេត្តក្រចេះ។
- ចូលរួមប្រជុំការងាលទ្ធកម្មវាយតម្លៃប្រគល់ ទទួល បញ្ចប់សុពលភាពជួសជុលផ្លូវជនបទក្រាលក្រួសក្រហម ០១ខ្សែ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ សាលប្រជុំសាលាខេត្ត។
- ចូលរួមប្រជុំស្ដីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៧-២០១៩ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ សាលប្រជុំសាលាខេត្ត។
- ចូលរួមពិធីសំណេះសំណាល និងផ្ដល់អណ្ដូងទឹកតាមសាលារៀន ថ្ងៃទី២៧-២៨ ខែមេសា ឆ្នាំ២០១៦ នៅឃុំដីរីផុង ឃុំកញ្ជរ ឃុំឆ្លូង និងឃុំខ្សាច់អណ្ដែត ស្រុកឆ្លូងខេត្តក្រចេះ។
- ចូលរួមពិធីសំណេះសំណាល និងផ្ដល់អណ្ដូងទឹកតាមសាលារៀន ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ឃុំកន្ទួត និងឃុំស្វាយជ្រះ។
- ចូលរួមសិក្ខាសាលា ស្ដីពីយេនឌ័រ និងកាចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០១៦ សាលប្រជុំសណ្ឋាគារលីជី។
- ចូលរួមពិធីផ្សព្វផ្សាយភារកិច្ចតួនាទីរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ និងផែនកាយុទ្ធសាស្រ្តជាតិ ស្ដីពីពិការភាព ឆ្នាំ២០១៤-២០១៨ ថ្ងៃទី០៤ ខែឧសភា ២០១៦ សាលប្រជុំសាលាខេត្ត។
- ចូលរួមប្រជុំផ្សព្វផ្សាយអនុក្រឹត្យលេខ៥៦ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ សាលប្រជុំសាលាខេត្ត។
- ចូលរួមប្រជុំពិនិត្យ ពិភាក្សាករណីសំណើសុំដីសម្បទានសង្គមកិច្ចរបស់ពលរដ្ឋ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦ សាលប្រជុំសាលាខេត្ត។

- ចូលរួមប្រជុំ ស្តីពី ការប៉ាន់ប្រមាណរហ័សអំពីស្ថានភាពគ្រោះរាំងស្ងួត ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ សាលប្រជុំសាលាខេត្ត។
- ចូលរួមប្រជុំត្រៀមរៀបចំពិធីមិទ្ទិញអបអរសាទរខួបលើកទី១៥៣ ទិវាអឌ្ឍចន្ទក្រហម ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ សាលប្រជុំសាលាខេត្ត។
- ចូលរួមប្រជុំត្រួតពិនិត្យតារាងប្រៀបធៀបកើន-ថយឆ្នាំ២០១៥ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ សាលប្រជុំមន្ទីរសេដ្ឋកិច្ច។
- ចូលរួមពិធីសូត្រមន្តចម្រើនព្រះជន្មព្រះករុណាព្រះបាទបរមនាថ នរោត្តម សីហមុនី ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ នៅសាលមហោស្រពខេត្ត។
- ចូលរួមពិធីសំណេះសំណាលជាមួយអតីតយុទ្ធជន ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ នៅសាលមហោស្រពខេត្ត។
- ចូលរួមប្រជុំពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ សាលប្រជុំក្រុមប្រឹក្សាខេត្ត។
- ចូលរួមធ្វើបទបង្ហាញស្តីពីគម្រោងទឹកស្អាត និងអនាម័យសុខភាពសហគមន៍ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ នៅសាលប្រជុំសណ្ឋាគារលីជី។
- ចូលរួមមហាសន្និបាតបង្គន់អនាម័យពិភពលោកនៅ សៀមរាប ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦។
- ចូលរួមពិធីបញ្ចុះបឋមសិលាសាលារៀននៅឃុំព្រែកសាម៉ាន់ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦។
- ចូលរួមជាមួយក្រុមការងារសិក្សាផលប៉ះពាល់ជាក់ស្តែង និងធ្វើអត្តសញ្ញាណកម្មដីលើទីតាំងដែលបានស្នើសុំសម្បទានសង្គមកិច្ចឃុំបឹងចារ និងឃុំកំពង់ចាម ថ្ងៃទី១ ដល់ទី៣ ខែមិថុនា ២០១៦។
- ចូលរួមប្រជុំជាមួយប្រតិភូអន្តរក្រសួងស្តីពី ការផ្ទេរសម្បទានដីសេដ្ឋកិច្ច ជូនក្រសួងកសិកម្ម និងផ្ទេរ តំបន់ដីការពារធម្មជាតិជូនក្រសួងបរិស្ថានវិញ នៅសាលប្រជុំសាលាខេត្តក្រចេះ ថ្ងៃទី០១ មិថុនា ឆ្នាំ២០១៦។
- ចូលរួមសិក្ខាសាលាស្តីពីលទ្ធភាពដាក់បញ្ចូលទីក្រុងបាត់ដំបង ក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោកនៅសាលប្រជុំខេត្តបាត់ដំបង ថ្ងៃទី០៦-០៨ ខែមិថុនា ឆ្នាំ២០១៦។
- ចូលរួមប្រជុំពិនិត្យ និងវាយតម្លៃលើសំណើតែងតាំង និងផ្លាស់ប្តូររភារកិច្ច នៅសាលប្រជុំវីដេអូខុនហ្វឺរិនសាលាខេត្តក្រចេះ ថ្ងៃទី០៣ ខែមិថុនា ២០១៦។
- ចូលរួមប្រជុំវាយតម្លៃប៉ាន់ស្មានផលប៉ះពាល់គ្រោះរាំងស្ងួត និងការជួយអន្តរាគមន៍ ថ្ងៃទី០៩ ខែមិថុនា ២០១៦ សាលប្រជុំសាលាខេត្ត។
- ចូលរួមពិធីសម្ពោធអាគារសិក្សាដែលជាអំណោយរបស់ Save the children ថ្ងៃទី០៨ ខែមិថុនា ២០១៦ ។
- ចូលរួមប្រជុំស្តីពីផែនការយុទ្ធសាស្ត្រថវិការជាតិឆ្នាំ ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ថ្ងៃទី០៨-០៩ ខែមិថុនា ឆ្នាំ២០១៦ នៅខេត្តបាត់ដំបង។
- ចូលរួមសិក្ខាសាលាចែករំលែកចំនេះដឹងស្តីពីការអភិវឌ្ឍន៍ជនបទ នៅថ្ងៃទី០៩ ខែមិថុនា ២០១៦ នៅសាលប្រជុំទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។

- ចូលរួមប្រារព្ធទិវាអតីតយុទ្ធជនកម្ពុជាថ្ងៃទី ១៣ ខែមិថុនា ២០១៦ សាលមហោស្រពខេត្តក្រចេះ។
- ចូលរួមប្រជុំក្រុមការងារបច្ចេកទេស សម្រាប់គម្រោងអនាម័យតាមសាលារៀន ថ្ងៃទី១៥ មិថុនា ២០១៦ នៅភោជនីយដ្ឋានទន្លេបាសាក់ II ភ្នំពេញ។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការប្រើប្រាស់ឯកសារព័ត៌ស្ថានភាព និងឯកសារព័ត៌ពិន្ទុវិស័យក្នុងដំណើរការកសាងកម្មវិធីវិនិយោគឃុំ សង្កាត់ឆ្នាំ២០១៧ ថ្ងៃទី១៥ មិថុនា ២០១៦ សាលប្រជុំសាលាខេត្តក្រចេះ
- ចូលរួមប្រជុំពិនិត្យលទ្ធផលសិក្សាដីសម្បទានសង្គមកិច្ចនៅឃុំកំពង់ចាម និងឃុំបឹងចារ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ សាលបប្រជុំក្រុមប្រឹក្សាខេត្ត។
- ចូលរួមសិក្ខាសាលា ផ្សព្វផ្សាយ និងបើកគម្រោងរបស់អង្គការសង្គ្រោះសត្វព្រៃ នៅស្រុកសៀមប៉ាង ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៦។
- ចូលរួមទិវាបរិស្ថានពិភពលោក ថ្ងៃទី១៥ មិថុនា ២០១៦ សាលមហោស្រពខេត្តក្រចេះ។
- ចូលរួមប្រជុំពិនិត្យ និងសម្រេច លើទិន្នន័យវាស់វែងទីតាំងដីសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុនវៀតណាម នៅស្រុកស្នួល ថ្ងៃទី១៥ មិថុនា ២០១៦ សាលប្រជុំសាលាខេត្តក្រចេះ។
- ចូលរួមប្រជុំស្តីពី ការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០១៧ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៦ សាលបប្រជុំសាលាខេត្តក្រចេះ។
- ចូលរួមទិវាប្រយុទ្ធប្រឆាំងពលកម្មកុមារ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ សាលមហោស្រពខេត្តក្រចេះ។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការងារគ្រប់គ្រងមន្ត្រីរាជការថ្ងៃទី២០-២១ ខែមិថុនា ឆ្នាំ២០១៦ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការយល់ដឹងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ថ្ងៃទី២២-២៤ មិថុនា ឆ្នាំ២០១៦ នៅសាលប្រជុំមន្ទីរសង្គមកិច្ចខេត្តក្រចេះ។
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីរបៀបប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្លូវ ថ្ងៃទី២២-២៣ ខែមិថុនា ឆ្នាំ២០១៦ នៅទីស្តីការក្រសួងអភិឌ្ឍន៍ជនបទ។
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ សណ្ឋាគារលីជី។

3. **សកម្មភាពតាមការិយាល័យ÷**

3.1. **ការិយាល័យរដ្ឋបាល និងបុគ្គលិក÷**

ក. ផ្នែកការងារលិខិតចូល÷ សរុបចំនួន ៣៤៨លេខ ក្នុងនោះមានៈ

- លិខិតចូលពីអង្គភាពនានាក្រោមន្ទីរ ចំនួន ២៩០ លេខ
- លិខិតក្រសួងសាមី និងអង្គភាពក្រោមឱវាទមន្ទីរ ចំនួន ៥៨ លេខ

ខ. <u>ផ្នែកការងារលិខិតចេញ</u>÷ សរុបចំនួន ៤០៤ លេខ ក្នុងនោះមានៈ

- លិខិតចេញទៅបណ្តាអង្គភាពនានាក្រោមន្ទី ចំនួន ២៣១ លេខ

- លិខិតចេញពាក់ព័ន្ធស្ថានភាពមន្ត្រីរាជការ ចំនួន ១២២ លេខ
- លិខិតចេញទូទៅ ( លិខិតអញ្ជើញ និងជូនដំណឹង) ចំនួន ១៦ លេខ
- លិខិតចេញទៅបណ្តាអង្គភាពនានា និងក្រសួងសាមី ចំនួន ៣៥ លេខ

គ. ផ្នែកបញ្ជីវត្ថុមាន÷ ពិនិត្យការចុះបញ្ជីវត្ថុមានប្រចាំថ្ងៃ ។

3.2. **ការិយាល័យផ្លូវជនបទ÷**

**សកម្មភាពការងារ**

- ក្រុមការងារនាយកដ្ឋានផ្លូវលំជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមការងារមន្ទីរអភិវឌ្ឍន៍ ជនបទខេត្តក្រចេះ ចុះសិក្សាផ្លូវចំនួន ១ខ្សែ ពីភូមិខ្សាច់វែង ទៅភូមិដារជ្រៃប្រវែង ១៦ ០០០ ម ដែលស្ថិតនៅឃុំកញ្ជរ ស្រុកឆ្លូង និងឃុំស្វាយជ្រះ ស្រុកស្នួល។
- ក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទចុះសិក្សាផ្លូវ ១ខ្សែ ពីភូមិអូរឬស្សី២ទៅភូមិបន្ទាយ ប្រវែង ៦ ១០០ ម ដែលស្ថិតនៅសង្កាត់អូរឬស្សី ក្រុងក្រចេះ និងឃុំគោលាប់ ស្រុកចិត្តបុរី ។
- ចុះស្រង់ទិន្នន័យផ្លូវជនបទ តាមប្រព័ន្ធ GPS សម្រាប់រៀបចំផែនទីក្នុងខេត្ត បានចំនួន ៧ ខ្សែ ៦០ ២០០ ម ដែលិតនៅឃុំកញ្ជរ ស្រុកឆ្លូង ឃុំបុសលាវ ស្រុកចិត្របុរី ឃុំស្វាយជ្រះ ស្រុកស្នួល
- ចុះធ្វើបច្ចុប្បន្នភាពផ្លូវតាមប្រព័ន្ធ PGS បាន១៤ខ្សែ ប្រវែង ២០៦,២០០ ម៉ែត្រ ដែលស្ថិតសនៅឃុំព្រែកប្រសព្វ ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ
- បញ្ជាក់បច្ចេកទេសមូលនីតិឃុំសង្កាត់របស់រដ្ឋបាលខេត្តក្រចេះបានចំនួន ០៦គម្រោង
- ចុះសិក្សាស្ពានអំពកប្រវែង ៣៤ ម៉ែត្រ តាមសំណើរបស់ប្រជាពលរដ្ឋក្នុងវេទិកាសាធារណៈស្ថិត នៅ ឃុំស្រែជិះ ស្រុកសំបូរ។
- ចុះសិក្សាផ្លូវចំនួន ២ ខ្សែ ប្រវែង ១០ ១៣៦ ម តាមសំណើរបស់ប្រជាពលរដ្ឋក្នុងវេទិកាសាធារណៈស្ថិតនៅឃុំស្នួលនិងឃុំ២ធ្នូស្រុកស្នួល។
- ចូលរួមពិនិត្យនិងវាយតម្លៃបញ្ចប់សុពលភាពផ្លូវជាមួយគណៈកម្មការអន្តរៈក្រសួង ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ២ ខ្សែ ប្រវែង ១២ ០០០ ម និងលូកាត់ផ្លូវ ៤ កន្លែងស្ថិតនៅឃុំឃ្សឹម ឃុំស្នួលស្រុកស្នួល។
- ចុះស្រង់ទិន្នន័យផ្លូវប្រភេទទី៤ បានចំនួន ១ ខ្សែ ប្រវែង ១៣ ៤០០ ម ស្ថិតនៅឃុំជ្រោយបន្ទាយស្រុកព្រែកប្រសព្វខេត្តក្រចេះ ។
- ចុះធ្វើបច្ចុប្បន្នភាពផ្លូវប្រភេទទី៣ បានចំនួន ៣ ខ្សែ ប្រវែង ៤០ ៨០០ ម ស្ថិត នៅឃុំថ្មី និងឃុំដារ ស្រុកចិត្របុរី ខេត្តក្រចេះ។

- លោកប្រធានកម្មវិធី RIP-III នៅ PMU និងតំណាងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និងអង្គភាពអនុវត្ត និងអង្គភាពអនុវត្តកម្មវិធី RIP III ខេត្តចុះពិនិត្យ និងវាយតម្លៃផ្លូវថៃទាំលក្ខណៈខួប ៥០% ចំនួន ៣ ខ្សែ ប្រវែង ២០ ៨០០ ម ស្ថិតនៅឃុំព្រែកប្រសព្វ ឃុំកំពង់គរ និងឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ។
- សិក្សាពិនិត្យ និងវាយតម្លៃស្ពានឈើទ្រុឌទ្រោម ២ កន្លែង ស្ថិតនៅឃុំកន្ទួត ស្រុកចិត្របុរី
- តំណាងក្រុមការងារក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និងក្រុមការងារលទ្ធកម្មខេត្ត ក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ ចុះពិនិត្យនិងវាយតម្លៃបញ្ចប់សុពលភាពការងារជួសជុលផ្លូវពីភូមិខ្សាត់ទៅស្ទឹងទ្រ ប្រវែង៦ ៨០០ មស្ថិតនៅឃុំតាម៉ៅស្រុកព្រែកប្រសព្វ។
- ចុះធ្វើបច្ចុប្បន្នភាពផ្លូវ ប្រភេទទី៣ និងប្រភេទទី៤ បានចំនួន ៣ខ្សែ ប្រវែង ២២ ០០០ ម ស្ថិត នៅឃុំសំបុក ឃុំចង្រ្កង់ ឃុំថ្មគ្រែ ឃុំគោលាប់ ឃុំកន្ទួត និងឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ។
- ចុះពិនិត្យការងារជួសជុលស្ពានឈើទ្រុឌទ្រោម ២ កន្លែង ស្ថិតនៅភូមិអន្ទង់វៀន ឃុំកន្ទួត ស្រុកចិត្របុរី បានចំនួន ៥ លើក។
- តំណាងក្រុមការងារក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ តំណាងក្រសួងអភិវឌ្ឍន៍ជនបទ ក្រុមការងារនាយកដ្ឋានផ្លូវលំជនបទ និងក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ ចុះពិនិត្យសិក្សា និងវាយតម្លៃ ជួសជុលបន្ទាន់ ផ្លូវភូមិស្ទឹងទ្រ ប្រវែង ៤ ៥០០ ម៉ែត្រ ស្ថិតនៅឃុំតាម៉ៅ ស្រុក ព្រែកប្រសព្វ។
- ចុះពិនិត្យការងារជួសជុលបន្ទាន់ផ្លូវភូមិស្ទឹងទ្រ ប្រវែង ៤ ៥០០ ម ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ បានចំនួន ១លើក។
- ចុះពិនិត្យការងារជួសជុលផ្លូវថៃទាំជាលក្ខណៈខួបរបស់គម្រោង RIP-III ចំនួន ៣ ខ្សែ ប្រវែង ២០ ៨០០ ម ស្ថិតនៅឃុំព្រែកប្រសព្វ ឃុំកំពង់គរ និងឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ចំនួន ១លើក។
- ចុះពិនិត្យការងារជួសជុលថៃទាំជាលក្ខណៈខួប ចំនួន ១ខ្សែ ប្រវែង ១០ ០០០ ម ស្ថិតនៅភូមិព្រែកចំឡាក់ (ឧបសម្ពន្ធ័ភូមិខ្សាច់វែង) ទៅភូមិដារជ្រៃ ឃុំកញ្ជរ ស្រុកឆ្លូង បានចំនួន ៣ លើក។
- ចុះធ្វើបច្ចុប្បន្នភាពផ្លូវ ប្រភេទទី៣ និងប្រភេទទី៤ បានចំនួន ៣ ខ្សែ ប្រវែង ១៧ ៣០០ ម ស្ថិតនៅឃុំស្នួល និងឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ។
- ចុះពិនិត្យ ការងារជួសជុលស្ពានឈើទ្រុឌទ្រោម ២កន្លែង ស្ថិតនៅភូមិអន្ទង់វៀន ឃុំកន្ទួត ស្រុកចិត្របុរី បានចំនួន ២ លើក។
- ចុះពិនិត្យការងារជួសជុលបន្ទាន់ផ្លូវភូមិស្ទឹងទ្រ ប្រវែង ៤ ៥០០ ម ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ បានចំនួន ២លើក។
- តំណាងក្រុមការងារក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ តំណាងក្រុមការងារអង្គភាពកម្មវិធី RIP-III និងអង្គភាពអនុវត្តកម្មវិធី RIP-III ខេត្តចុះពិនិត្យនិងវាយតម្លៃប្រគល់-ទទួល ផ្លូវថៃទាំជាលក្ខណៈខួបរបស់គម្រោង

RIP-III ចំនួន ៣ខ្សែ ប្រវែង ២០ ៨០០ ម ស្ថិតនៅឃុំព្រែកប្រសព្វ ឃុំកំពង់គរ និងឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ។

- ចុះពិនិត្យការងារជួសជុលថែទាំជាលក្ខណៈខួប ចំនួន ០១ ខ្សែ ប្រវែង ១០ ០០០ ម៉ែត្រ ស្ថិតនៅភូមិព្រែកចំឡាក់ (ឧបសម្ពន្ធ័ភូមិខ្សាច់វែង) ទៅភូមិដារជ្រៃ ឃុំកញ្ជរ ស្រុកឆ្លូង បានចំនួន ២លើក ។
- ចុះពិនិត្យការងារជួសជុលថែទាំជាលក្ខណៈប្រចាំ ចំនួន ៣ ខ្សែ ប្រវែង ៥១ ០០០ ម៉ែត្រ ស្ថិតនៅឃុំកំពង់ដំរី ស្រុកឆ្លូង និងឃុំអូរគ្រៀង ស្រុកសំបូរ បានចំនួន ១ លើក។
- តំណាងក្រុមការងារនាយកដ្ឋានផ្លូវលំជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ ចុះពិនិត្យនិងវាយតម្លៃបញ្ចប់ការងារជួសជុលបន្ទាន់ផ្លូវភូមិស្ទឹងទ្រ ប្រវែង ៤ ៥០០ ម៉ែត្រ ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ។

**លទ្ធផលការងារ**

- ការងារផ្លូវថែទាំជាលក្ខណៈខួបរបស់គម្រោង RIP-III ចំនួន៣ខ្សែ ប្រវែង ២០ ៨០០ម៉ែត្រ ស្ថិតនៅឃុំព្រែកប្រសព្វ ឃុំកំពង់គរ ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ លទ្ធផលសម្រេចបាន ១០០ %។
- ការងារជួសជុលថែទាំជាលក្ខណៈខួប ចំនួន ១ ខ្សែ ប្រវែង ១០ ០០០ ម ស្ថិតនៅភូមិព្រែកចំឡាក់ (ឧបសម្ពន្ធ័ភូមិខ្សាច់វែង) ទៅភូមិដារជ្រៃ ឃុំកញ្ជរ ស្រុកឆ្លូង លទ្ធផលសម្រេចបាន ៤០%។
- ការងារជួសជុលបន្ទាន់ផ្លូវភូមិស្ទឹងទ្រ ប្រវែង ៤ ៥០០ ម ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ លទ្ធផលសម្រេចបាន ១០០%។
- ការងារជួសជុលស្ពានឈើទ្រុឌទ្រោម ២កន្លែង ស្ថិតនៅភូមិអន្ទង់វៀន ឃុំកន្ទួត ស្រុកចិត្របុរី លទ្ធផលសម្រេចបាន ១០០%។
- ការងារជួសជុលផ្លូវថែទាំជាលក្ខណៈប្រចាំ ចំនួន ៣ខ្សែ ប្រវែង ៥១ ០០០ ម ស្ថិតនៅ ឃុំកំពង់ដំរី ស្រុកឆ្លូង និងឃុំអូរគ្រៀង ស្រុកសំបូរ លទ្ធផលសម្រេចបាន ៣០%។

### 3.3. ការិយាល័យផ្គត់ផ្គង់ទឹកជនបទ÷

- ជួសជុលអណ្តូងស្នប់អាហ្វ្រីដេសបានចំនួន **៤០ អណ្តូង** និងសាងសង់អណ្តូងស្នប់ថ្មីបានចំនួន **០១ អណ្តូង**
  - o ស្រុកស្នួលបានចំនួន ០៧ អណ្តូង នៅឃុំស្វាយជ្រះ
  - o ស្រុកព្រែកប្រសព្វបានចំនួន ០៦ អណ្តូង នៅឃុំជ្រោយបន្ទាយ
  - o ស្រុកចិត្របុរីបានចំនួន ១៣ អណ្តូង នៅឃុំដារ ១០ ឃុំសំបុក ០១ ឃុំថ្មី ០២
  - o ស្រុកឆ្លូងបានចំនួន ១១ អណ្តូង នៅឃុំកំពង់ដំរី ០៨ ឃុំដំរីផុង ០៣
  - o ក្រុងក្រចេះបានចំនួន ០១ អណ្តូង នៅសង្កាត់ក្រគរ

- o ស្រុកសំបូរបានចំនួន ០២ អណ្តូង នៅឃុំក្បាលដំរី (និងសាងសង់អណ្តូងស្នប់ថ្មីបានចំនួន ០១ អណ្តូង នៅឃុំស្រែជិះ) ។

3.4. **ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ÷** (គ្មានសកម្មភាព)

3.5. **ការិយាល័យអភិវឌ្ឍន៍សហគមន៍÷**

- សហការជាមួយអង្គការឆាលហ្វានកម្ពុជាប្រចាំខេត្តក្រចេះ ដឹកនាំគ.អ.ភ ក្រុមប្រឹក្សាឃុំ និង តំណាងស្រុកឆ្លូង ទៅធ្វើទស្សនកិច្ចសិក្សានៅខេត្តកំពត និងកំពង់ស្ពឺ ដែលមានអ្នកចូលរួមសរុប ៤៨ នាក់ ក្នុងនោះស្ត្រីមានចំនួន ១៤ នាក់ ។
- ចុះត្រួតពិនិត្យតាមដានសកម្មភាព និងធ្វើបច្ចុប្បន្នភាពសមាសភាព គ.អ.ភ បានចំនួន ២ ស្រុក ៨ឃុំ ៦០ភូមិ ស្រុកស្នួលមាន ចំនួន៥ឃុំ ឃុំស្វាយជ្រះ ឃុំឃ្សឹម ឃុំស្នួល ឃុំស្រែចារ និងឃុំ២ធ្នូ ស្រុកចិត្របុរីមាន ចំនួន៣ឃុំ ឃុំកន្ទួត ឃុំដារ និងឃុំថ្មី ។

3.6. **ការិយាល័យជនជាតិដើមភាគតិច÷** (គ្មានសកម្មភាព)

3.7. **ការិយាល័យថែទាំសុខភាពជនបទ÷**

- ផ្សព្វផ្សាយ សកម្មភាពស្តីពីការលើកកម្ពស់អនាម័យតាមសហគមន៍ និងពង្រឹងបណ្តាញជនបង្គោលស្មគ្រ័ចិត្តភូមិ នៅស្រុកសំបូរអ្នកចូលរួម ៦៩ នាក់ ស្រី ២៣ នាក់ ក្នុងនោះ÷
  - o ឃុំកោះខ្មែរ ៣៦ នាក់ ស្ត្រី ១៣ នាក់
  - o ឃុំវឌ្ឍនៈ ៣៣ នាក់ ស្ត្រី ១០ នាក់
- បំផុសអោយប្រជាពលរដ្ឋចូលរួមស្មគ្រ័ចិត្តសាសង់បង្គន់ខ្លួនឯង
  - o ឃុំព្រែកសាម៉ាន់ ចំនួន ៣៨ គ្រួសារ
  - o ឃុំកញ្ជរ ចំនួន ២២ គ្រួសារ
  - o ឃុំដារ ចំនួន ២៣ គ្រួសារ
  - o ឃុំឆ្លូង ចំនួន ៥២ គ្រួសារ ។

4. **ទិសដៅបន្ត÷**

- ចុះជួសជុលថែទាំជាលក្ខណៈខួប ចំនួន ១ ខ្សែ ប្រវែង ១០ ០០០ ម ស្ថិតនៅភូមិព្រែកចំឡាក់ (ឧបសម្ពន្ធ័ភូមិខ្សាច់វែង) ទៅភូមិដារជ្រៃ ឃុំកញ្ជរ ស្រុកឆ្លូង ។
- ចុះជួសជុលផ្លូវថែទាំជាលក្ខណៈប្រចាំ ចំនួន ៣ខ្សែ ប្រវែង ៥១ ០០០ ម ស្ថិតនៅឃុំកំពង់ដំរី ស្រុកឆ្លូង និងឃុំអូរគ្រៀង ស្រុកសំបូរ។
- ចុះស្រង់ទិន្នន័យនិង ធ្វើបច្ចុប្បន្នភាពផ្លូវស្រុកចិត្របុរី ស្រុកសំបូរ និងស្រុកស្នួល ដើម្បីរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវនិងផែនទីក្នុងខេត្តក្រចេះ។

- បន្តចុះពិនិត្យការងារជួសជុលនិងសាងសង់អណ្តូងស្នប់ ស្តារស្រះសហគមន៍ សាងសង់អាងត្រង់ទឹកភ្លៀង នៅស្រុកចិត្របុរី ស្រុកស្នួល ស្រុកសំបូរ ស្រុកព្រែកប្រសព្វ។
- តាមដានសកម្មភាព និងធ្វើបច្ចុប្បន្នភាព គ.អ.ភ នៅស្រុកឆ្លូង។
- បន្តការបំផុសអោយប្រជាពលរដ្ឋចូលរួមសាងសង់បង្គន់ដោយខ្លួនឯង ក្នុងស្រុកឆ្លូង ស្រុកចិត្របុរី ស្រុកព្រែកប្រសព្វ ស្រុកសំបូរ និងក្រុងក្រចេះ ។
- ផ្តល់សម្ភារៈសាងសង់បង្គន់នៅឃុំកោះខ្ញែរ និង ឃុំវឌ្ឍនៈ ។

**ប្រធានមន្ទីរ**